# ទស្សនាវដ្ដីវិទ្យាសាស្ត្រ

# THE SCIENTIFIC JOURNAL

លេខ 2
VOL. 2

ការផ្សាយរបស់វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា The Publication of the International Relations Institute of Cambodia

## ការណ៍ពិតជុំវិញការបង្កក ទំនាក់ទំនងការទូត រវាងកម្ពុជា និងថៃ




0645 8
ATB CENTER
$ 2.00

ភ្នំពេញ កម្ពុជា

ខែធ្នូ ឆ្នាំ២០០៩

# មាតិកា

## Table of Contents


- ការណ៍ពិតជុំវិញការបង្កកទំនាក់ទំនងការទូតរវាងកម្ពុជា និងថៃ........ 1
  *The Truth over the Frozen Diplomatic Relations between Cambodia and Thailand*
- សេចក្តីថ្លែងការណ៍របស់វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹងការបង្កកទំនាក់ទំនងការទូតរវាងកម្ពុជា និងថៃ........12
  *The Statement of the International Relations Institute of Cambodia dated 06 November 2009 regarding the Frozen Diplomatic Relations between Cambodia and Thailand*
- ភាពតានតឹងរវាងចិន និងសហរដ្ឋអាមេរិកនៅសមុទ្រចិនខាងត្បូង........15
  *Tension between China and the United States of America at South China Sea*
- ការកសាងផែនការរចនាសម្ព័ន្ធរូបវន្តពាក់ព័ន្ធនឹងលំនៅឋាន........24
  *Housing Physical Structure Planning*
- បរិបទនយោបាយអន្តរជាតិក្នុងសង្គ្រាមវៀតណាម........31
  *International Context in Vietnam War*
- ការវិវត្តនៃតារាងពន្ធគយកម្ពុជា ឆ្នាំ១៩៩៣-២០០៧........38
  *The Evolution of Cambodia's Tariff 1993-2007*
- ស្វែងយល់ពីការគ្រប់គ្រងសហជីពនៅកម្ពុជា........43
  *Understanding Labour Union Management in Cambodia*
- បញ្ហាប្រឈមក្នុងការស្តារ និងអភិវឌ្ឍន៍រាជធានីភ្នំពេញ........47
  *The Challenges in Rehabilitation and Development of Phnom Penh City*
- វិបត្តិហិរញ្ញវត្ថុនៅសហរដ្ឋអាមេរិក និងអឺរ៉ុប និងផលប៉ះពាល់ចំពោះសេដ្ឋកិច្ចអាស៊ី........57
  *Financial Crisis in the U.S. and Europe and Its Impact to Asian Economy*
- ប្រវត្តិ និងការវិវត្តវិស័យឧត្តមសិក្សានៅកម្ពុជា........66
  *History and Evolution of Higher Education in Cambodia*


*ទស្សនាវដ្តីវិទ្យាសាស្ត្រ នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ទទួលចុះផ្សាយនូវរាល់អត្ថបទវិទ្យាសាស្ត្រ ស្នាដៃស្រាវជ្រាវ សម្រង់អត្ថបទពីសៀវភៅល្បីៗ និងសម្រង់អត្ថបទពីនិក្ខេបបទរបស់បេក្ខជនបណ្ឌិតគ្រប់ឯកទេសផ្នែកវិទ្យាសាស្ត្រសង្គមពីគ្រប់មជ្ឈដ្ឋាន ទាំងក្នុងនិងក្រៅប្រទេសដែលមានលក្ខណៈវិទ្យាសាស្ត្រ និងមានសារប្រយោជន៍សម្រាប់មនុស្សជាតិ សង្គមជាតិ និងភពផែនដី ហើយយើងខ្ញុំក៏ទទួលចុះផ្សាយអត្ថបទផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផងដែរ។ ទូរស័ព្ទទំនាក់ទំនង ៖ ០៩៧ ៧០៨ ១១១១។*

***សូមអរគុណ!***


**ការិយាល័យនិពន្ធ ៖ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា**

មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប (ពោធិចិនតុង) ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ ៖ ០២៣ ៨៩ ០១ ៦៧, អ៊ីម៉ែល ៖ iric@iric.gov.kh, k_phea@yahoo.com

# ប្រវត្តិ និងការវិវត្តវិស័យឧត្តមសិក្សានៅកម្ពុជា

***កំណត់ការិយាល័យនិពន្ធ*** *៖ អត្ថបទខាងក្រោមនេះជាស្នាដៃស្រាវជ្រាវរបស់លោក* ***ចៅ លិន*** *បេក្ខជនបណ្ឌិតវិទ្យាសាស្ត្រនអប់រំ ជំនាន់ទី១ វគ្គទី១ នៃរាជបណ្ឌិតសភាកម្ពុជា។ អត្ថបទនេះត្រូវបានលោកសាស្ត្រាចារ្យបណ្ឌិត* ***ចាន់ រដ្ឋសុផា*** *ដែលជាសាស្ត្រាចារ្យណែនាំ ឯកភាពឲ្យផ្សព្វផ្សាយជាសាធារណៈក្នុងគោលបំណងទទួលយកនូវការរិះគន់ស្ថាបនាពីសំណាក់មិត្តអ្នកអាន ដើម្បីឲ្យបេក្ខជនបណ្ឌិត អាចយកគំនិតទាំងនោះទៅកែលម្អនិក្ខេបបទបណ្ឌិតរបស់ខ្លួន។*

## ១- សេចក្ដីផ្ដើម

ការអប់រំសំដៅដល់កិច្ចដំណើរការសិក្សា ដើម្បីអភិវឌ្ឍន៍ខាងបុគ្គលិកលក្ខណៈ បញ្ញាសម្បទា កាយ-ចិត្តសម្បទា តាមរាល់សកម្មភាពអ្នកសិក្សា ដើម្បីទទួលបាននូវចំណេះដឹងមូលដ្ឋាន ចំណេះដឹងជំនាញ ចំណេះធ្វើ សមត្ថភាពផ្ទាល់ខ្លួន មានសេចក្ដីថ្លៃថ្នូរ គុណធម៌ សីលធម៌ សម្រាប់មនុស្សជាតិទាំងមូលនៅលើពិភពលោក។

ការអប់រំកម្រិតឧត្តមសិក្សា គឺសំដៅដល់ការអប់រំកម្រិតខ្ពស់បំផុត រួមមានកម្រិតអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដែលនាំទៅដល់ការទទួលបាននូវការអប់រំកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតមានការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិ ឬតម្លៃកម្រិតសមមូល។ គោលនយោបាយ គោលការណ៍ ផែនការយុទ្ធសាស្ត្រអប់រំ ត្រូវបានកសាងផែនការគោលសម្រាប់ការអភិវឌ្ឍវិស័យអប់រំ អនុលោមតាមគោលនយោបាយអប់រំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងការត្រួតពិនិត្យ កែសម្រួលគោលនយោបាយ គោលការណ៍ផែនការ និងយុទ្ធសាស្ត្រអប់រំស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល[1]។

## ២- គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាពីឆ្នាំ១៩៤៦ ដល់ឆ្នាំ ១៩៧០

វិស័យឧត្តមសិក្សានៅកម្ពុជា ទើបចាប់បដិសន្ធិក្រោយចប់សង្គ្រាមលោកលើកទី២ គឺក្នុងឆ្នាំ១៩៤៦ និងមានការកកើតគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាជាបន្តបន្ទាប់ ដូចតទៅ ៖

- ឆ្នាំ១៩៤៦ ៖ កើតមានសាលាមន្ត្រីសុខាភិបាល[2]។ ឆ្នាំ១៩៥៣ បានដូរឈ្មោះទៅជាសាលាភូមិន្ទវិជ្ជាពេទ្យវិញ[3]។ ឆ្នាំ១៩៦២ បានដូរឈ្មោះទៅជាមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថកម្ម និងវិទ្យាសាស្ត្រឱសថកម្ម[4]។
- ឆ្នាំ១៩៤៩ ៖ កើតមានវិទ្យាស្ថានជាតិផ្នែកច្បាប់ និងសេដ្ឋកិច្ច។ ឆ្នាំ១៩៥៣ បានដូរឈ្មោះមកជាវិទ្យាស្ថានជាតិយុត្តិធម្មសាស្ត្រ និងសេដ្ឋសាស្ត្រវិញ។ ឆ្នាំ១៩៥៧ បានដូរឈ្មោះជាមហាវិទ្យាល័យនីតិសាស្ត្រ។ សាលាទាំងពីរនេះ គ្រប់គ្រងកម្មវិធីសិក្សា និងការបង្រៀនជាឧបសម្ព័ន្ធរបស់សាលាពេទ្យ និងសាលាច្បាប់របស់បារាំងនៅក្រុងប៉ារីស[5]។
- ឆ្នាំ១៩៥៤ ៖ កើតមានពុទ្ធិកសាកលវិទ្យាល័យ ជាគ្រឹះស្ថានឧត្តមសិក្សាផ្នែកព្រះពុទ្ធសាសនា។ ឆ្នាំ១៩៥៤ បានដូរឈ្មោះថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ[6]។ ឆ្នាំ១៩៥៥ បានដូរឈ្មោះជាពុទ្ធកសាកលវិទ្យាល័យព្រះសីហនុរាជវិញ[7]។

- ឆ្នាំ១៩៦៥ ៖ មានការកកើតគ្រឹះស្ថានឧត្ដមសិក្សា ជាច្រើន ដូចជា ៖
  - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បង្កើតឡើងតាមព្រះរាជក្រមលេខ២២៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទបច្ចេកទេសបង្កើតឡើងតាមព្រះរាជក្រមលេខ ២២៥ ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បង្កើតឡើងតាមព្រះរាជក្រមលេខ២២៦ ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទ វិទ្យាសាស្ត្រកសិកម្ម បង្កើតឡើងតាមព្រះរាជក្រម លេខ ២៨៤ ប.រ. ចុះថ្ងៃ ទី២៦ ខែឧសភា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាប្រជារាស្ត្រ បង្កើតឡើងតាមព្រះរាជក្រមលេខ២៥៨ ប.រ. ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទកំពង់ចាម បង្កើតតាមព្រះរាជក្រមលេខ ២២៧ ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទបាត់ដំបងបង្កើតឡើងតាមព្រះរាជក្រមលេខ ២២៩ ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។
  - សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត បង្កើតឡើងតាមព្រះរាជក្រមលេខ ២២៨ ប.រ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។

និស្សិតខ្មែរដែលសិក្សានៅគ្រឹះស្ថានឧត្ដមសិក្សាក្នុងស្រុកពីឆ្នាំសិក្សា១៩៦៤-៦៥ ដល់ ១៩៦៩-៧០ មានចំនួនសរុបទាំងអស់ គឺ ២២.៨៥៩ នាក់[៦]។

គ្រឹះស្ថានឧត្ដមសិក្សានៅកម្ពុជាពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ នេះបានបង្ហាញឱ្យឃើញនូវការរីកចម្រើននិងការវិវត្តន៍វិស័យអប់រំឧត្ដមសិក្សានៅកម្ពុជា ហើយការបង្កើតគ្រឹះស្ថានឧត្ដមសិក្សា គឺដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍របស់សង្គម ជាពិសេសការកើនឡើងចំនួនសិស្សនៅមធ្យមសិក្សា។ ការបណ្ដុះបណ្ដាលនៅកម្រិតឧត្ដមសិក្សា គេបានកំណត់បញ្ហាចម្បងដោយផ្ដោតទៅលើការគ្រប់គ្រង ការរៀបចំកម្មវិធីសិក្សា ដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់សង្គម។

## ៣- គ្រឹះស្ថានឧត្ដមសិក្សាសម័យសាធារណរដ្ឋខ្មែរ ពីឆ្នាំ១៩៧០ ដល់ ១៩៧៥

គ្រឹះស្ថានឧត្ដមសិក្សានៅសម័យនេះមិនមានការប្រែប្រួលទេគឺដូចសម័យសង្គមរាស្ត្រនិយមដែរ។ និស្សិតខ្មែរ ដែលសិក្សានៅគ្រឹះស្ថានឧត្ដមសិក្សាក្នុងស្រុកពីឆ្នាំសិក្សា១៩៧០-៧១ និង ១៩៧១-៧២ មានចំនួនសរុបទាំងអស់ ១៣.៧០៧ នាក់។ នៅឆ្នាំ១៩៧១ សាកលវិទ្យាល័យនៅតាមខេត្ត មានកំពង់ចាម បាត់ដំបង តាកែវ-កំពត ត្រូវបានបិទទ្វារ ព្រោះបញ្ហាសន្តិសុខ។ និស្សិតនិងសាស្ត្រាចារ្យមួយចំនួនត្រូវបានបាត់ខ្លួន និងមួយចំនួនទៀតបានភៀសខ្លួនមកភ្នំពេញបន្តការសិក្សា ធ្វើឱ្យនិស្សិតនៅតាមគ្រឹះស្ថានឧត្ដមសិក្សាក្នុងក្រុងភ្នំពេញកើនចំនួនឡើងជាង ១ម៉ឺននាក់[៧]។

និស្សិតខ្មែរ ដែលបន្តការសិក្សាផ្នែកឧត្ដមសិក្សានៅបរទេស ឆ្នាំសិក្សា ១៩៧៣-៧៤ និង ១៩៧៤-៧៥ មាន ៖

- និស្សិតអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង បែលហ្ស៊ិក ស្វីស មានសរុប ៥១នាក់ (ឆ្នាំ១៩៧៣-៧៤)។

- និស្សិតអាហារូបករណ៍របស់រដ្ឋាភិបាលនិងអង្គការនានានៅអូស្ត្រាលី អ៊ឺរ៉ុប និងអាមេរិក មាន សហព័ន្ធអាឡឺម៉ង់, អង់គ្លេស, អូស្ត្រាលី, ប៊ែលហ្ស៊ិក, ប៊ុលហ្គារី, កាណាដា, បារាំង, ហាវ៉ៃ, ជប៉ុន, ឆេកូស្លូវ៉ាគី, សហរដ្ឋ អាមេរិក, សហភាព សូវៀត, យូហ្គោស្លាវី សរុបទាំងអស់ ៣៦៥នាក់ (ឆ្នាំ១៩៧៤-៧៥)។

- និស្សិតដែលទៅសិក្សានៅបរទេស ដោយសោហ៊ុយគ្រួសារ/ខ្លួនឯង ដូចជា អង់គ្លេស, ប៊ែលហ្ស៊ិក, កាណាដា, សាធារណរដ្ឋប្រជាមានិតចិន, បារាំង, ហុងកុង, ស្វីស សរុបទាំងអស់ ៨៤នាក់។ ដូច្នេះ និស្សិតខ្មែរ ដែលបន្តការសិក្សា ផ្នែកឧត្តមសិក្សានៅបរទេសលើពិភពលោក មានចំនួនសរុប គឺ ៥០១ នាក់[10]។

ក្នុងរបបសាធារណរដ្ឋខ្មែរ និស្សិតមានពេលវេលារៀនបានតិចតួចណាស់ ហើយគុណភាពនៃការអប់រំឧត្តមសិក្សាបានធ្លាក់ចុះ។ គេឃើញមានកូដកម្ម បាតុកម្មកើនឡើងជាញឹកញយដង ហើយទំនិញនិងគ្រឿងឧបភោគនៅទីផ្សារ ចេះតែឡើងថ្លៃជារៀងរាល់ថ្ងៃរហូតធ្វើឱ្យរបបនេះ ត្រូវដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

## ៤- វិស័យអប់រំឧត្តមសិក្សាក្រោយឆ្នាំ ១៩៧៩

គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្រោយឆ្នាំ១៩៧៩ បានស្ថិតនៅក្រោមសិទ្ធិគ្រប់គ្រងនិងចាត់ចែងរបស់ក្រសួងផ្សេងៗគ្នា ស្របតាមជំនាញវិជ្ជាជីវៈ។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនីមួយៗត្រូវពង្រឹងគុណភាពនៃការបណ្តុះបណ្តាលធនធានមនុស្សទៅតាមជំនាញ ដោយយកចិត្តទុកដាក់ និងតាមដានលើសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យ និងសកម្មភាពសិក្សាស្រាវជ្រាវរបស់និស្សិត។ រដ្ឋាភិបាលកម្ពុជាបានបញ្ជូននិស្សិតទៅសិក្សានៅបរទេស ក្រោយឆ្នាំ១៩៧៩ មកសព្វថ្ងៃ គឺចាប់ពីឆ្នាំ ១៩៨០ ដល់ ២០០៨ មានចំនួនសរុបទាំងអស់ គឺ ១១.៤៧៧ នាក់ ស្រីចំនួន ២.០៤៣នាក់[11]។ ចាប់ពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៩ គោលការណ៍អប់រំជាមូលដ្ឋានរបស់ក្រសួងអប់រំ ចាប់ផ្តើមបង្កើតជាសាលាមតេយ្យសិក្សា សាលាបឋមសិក្សា សាលាមធ្យមសិក្សា សាលាបច្ចេកទេសជំនាញវិជ្ជាជីវៈ និងឧត្តមសិក្សា ក្រោមការជួយឧបត្ថម្ភពីប្រទេសជាសម្ព័ន្ធមិត្តក្នុងប្លុកកុំម្មុយនីស្ត និងសង្គមនិយម។

## ៥- គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ពីឆ្នាំ១៩៧៩ មកដល់សព្វថ្ងៃ

គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាពីឆ្នាំ១៩៧៩-១៩៩៣ ៖ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមានចំនួន ៩ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង៤ គឺ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម, ក្រសួងសុខាភិបាល និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាពីឆ្នាំ១៩៩៣ មកសព្វថ្ងៃ ៖ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ (សាធារណៈនិងឯកជន) មានចំនួន ៧០ នៅតាមខេត្តក្រុង ចំនួន ១៩ ទូទាំងប្រទេស លើកលែងតែខេត្តក្រុង ៥ ទេ ដែលគ្មានគ្រឹះស្ថានឧត្តមសិក្សា។

គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ មានចំនួន៣០ ដែលគ្រប់គ្រងនិងចាត់ចែងដោយក្រសួងសាមីចំនួន១០ និងទីស្តីការគណៈរដ្ឋមន្ត្រី។ គ្រឹះស្ថានឧត្តមសិក្សាទាំងនេះសុទ្ធតែមានទីតាំងគោល និងសាខារបស់ខ្លួននៅតាមខេត្ត-ក្រុង។ គ្រឹះស្ថានឧត្តមសិក្សាឯកជន មានចំនួន៤០ទៀត ដែលគ្រប់គ្រង និងចាត់ចែងដោយក្រសួងអប់រំ យុវជន និងកីឡា។ គ្រឹះស្ថានឧត្តមសិក្សាទាំងនេះសុទ្ធតែមានទីតាំងគោល និងសាខារបស់ខ្លួននៅតាមខេត្ត-ក្រុង។ ចាប់តាំងពីឆ្នាំ២០០៤ ដល់ ២០០៩ រាជរដ្ឋាភិបាល និងក្រសួងអប់រំ

យុវជន និងកីឡា បានបញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជន ចំនួន ៩ នៅក្នុងប្រទេសកម្ពុជា។

តាមជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល គឺពង្រឹងលើវិស័យអប់រំ ដោយបើកទូលាយឱ្យដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធចូលរួមស្របតាមសេដ្ឋកិច្ចទីផ្សារសេរី។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ វិស័យឧត្តមសិក្សាបានឈានចូលទៅក្នុងយុគសម័យមួយនៃការធ្វើសម្បទា និងការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងដំណាក់កាលថ្មីចុងក្រោយបង្អស់នៃការប្រែប្រួលផ្នែកឧត្តមសិក្សា ដោយសារចំនួននិស្សិតកើនឡើងគួរឱ្យកត់សម្គាល់។ តម្រូវការនេះ ធ្វើឱ្យគ្រឹះស្ថានឧត្តមសិក្សាឯកជនកើតមានឡើងជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលមានតួនាទីត្រួតពិនិត្យលើគុណភាព និងបទដ្ឋានគតិយុត្តិទាំងឡាយ ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ ។

## ៦- ការអនុវត្តកម្មវិធីសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

ខ្លឹមសារកម្មវិធីសិក្សាតាមប្រព័ន្ធម៉ោង ៖ ប្រព័ន្ធម៉ោងត្រូវបានគេរៀបចំទៅតាមមុខវិជ្ជានីមួយៗ ដែលគេត្រូវយកមកបង្រៀន។ ចំនួនម៉ោងសរុបនៃមុខវិជ្ជា ត្រូវបានបែងចែកទៅតាមឆមាសនៃឆ្នាំសិក្សា ដើម្បីឈានទៅរកស្តង់ដាររបស់ក្រសួងអប់រំ យុវជន និងកីឡា កំណត់ឱ្យ។ ខ្លឹមសារកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ទើបតែចាប់អនុវត្តពីឆ្នាំ២០០២ មកសព្វថ្ងៃនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជននៅកម្ពុជា ដើម្បីឱ្យដូចបណ្តាប្រទេសនានាក្នុងសមាគមអាស៊ាន និងលើពិភពលោក។ គោលបំណងនៃការសិក្សាតាមប្រព័ន្ធក្រេឌីត គឺ ៖

- និស្សិតអាចព្យួរការសិក្សាទៅតាមលទ្ធភាព ក្នុងការបង់ថវិកាចូលរៀនបន្តមុខជំនាញ
- និស្សិតអាចផ្ទេរការសិក្សា ពីគ្រឹះស្ថានឧត្តមសិក្សាមួយទៅគ្រឹះស្ថានឧត្តមសិក្សាមួយទៀតបាន
- សំដៅពង្រឹង និងធានាគុណភាព ឬស្តង់ដារបែបណាមួយ ទៅតាមពេលវេលា និងទីកន្លែង
- ក្នុង ១មុខវិជ្ជាឯកទេស អាចយកមកបង្រៀន ១ក្រេឌីត[12]កន្លះទៅ ៣ក្រេឌីតក្នុង ១ឆមាស
- ១ក្រេឌីតនៅប្រទេសកម្ពុជាគេគិត១៦ម៉ោង។ ១ឆមាសគិត ១៦សប្តាហ៍ រាប់ទាំងពេលប្រឡងផង ត្រូវជា៤ខែ។
- ការសិក្សាមុខវិជ្ជា១ មានរយៈពេល ៣ម៉ោងក្នុង ១សប្តាហ៍ក្នុង ១ឆមាស និស្សិតអាចសន្សំបាន ៣ក្រេឌីត។

## ៧- និស្សិតកំពុងសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង ឯកជន ៖[13]

### ក- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា ២០០៨-០៩ សរុបទូទាំងប្រទេស មាន ៖

| | | |
|---|---|---|
| - ថ្នាក់បណ្ឌិត | សរុប ៖ ៨៦៤នាក់ | ស្រី ៖ ៤៧នាក់ (៥,៤៣%) |
| - ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | សរុប ៖ ១២ ១០៦នាក់ | ស្រី ៖ ១ ៩៦៧នាក់ (១៦,២៤%) |
| - ថ្នាក់បរិញ្ញាបត្រ | សរុប ៖ ១៣៦ ៨៨៦នាក់ | ស្រី ៖ ៥២ ៦២៥នាក់ (៣៨,៤៥%) |
| *ក្នុងនេះនិស្សិតអាហារូបករណ៍ ៖ ១៤ ៨៧៥ នាក់* | | *ស្រី ៖ ៥ ៨១២នាក់ (៣៩,០៧%)* |
| - ថ្នាក់បរិញ្ញាបត្ររង | សរុប ៖ ១៧ ១៦២នាក់ | ស្រី ៖ ៥ ០៨៦នាក់ (២៩,៦៣%) |
| *ក្នុងនេះនិស្សិតអាហារូបករណ៍សរុប ៖ ២ ៥៦៩នាក់* | | *ស្រី ៖ ៩១២នាក់ ( ៣៥,៥០%)* |

### ខ- និស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា ២០០៨-០៩ សរុបទូទាំងប្រទេស មាន ៖

| | | |
|---|---|---|
| - ថ្នាក់បណ្ឌិត | សរុប ៖ ២៦នាក់ | ស្រី ៖ ១នាក់ (៣,៨៤%) |

- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សរុប ៖ ៤១២នាក់ ស្រី ៖ ១១០នាក់ (២៦,៦៩%)
- ថ្នាក់បរិញ្ញាបត្រ សរុប ៖ ២៤ ១៣៦នាក់ ស្រី ៖ ៩ ២២៦នាក់ (៣៨,២២%)
- ថ្នាក់បរិញ្ញាបត្ររង សរុប ៖ ៨ ១០៦នាក់ ស្រី ៖ ២ ១០១នាក់ (២៥,៩១%)

## ៨- សេចក្តីសន្និដ្ឋាន

វិស័យអប់រំឧត្តមសិក្សាពីឆ្នាំ១៩៧៩ ដល់១៩៩៣ នៅកម្ពុជាមិនបានអនុវត្តឱ្យបានសមស្របទៅតាមនិយាម និងរចនាសម្ព័ន្ធចាត់តាំងត្រឹមត្រូវតាមស្តង់ដារតំបន់និងអន្តរជាតិនៅឡើយ ប៉ុន្តែផ្លែផ្កា (គុណភាព) នៃការអប់រំអាចទទួលយកបាន ។ ចាប់ពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន ការអប់រំឧត្តមសិក្សាបានកែប្រែពីប្រព័ន្ធម៉ោងទៅជាប្រព័ន្ធក្រេឌីតវិញ។ រចនាសម្ព័ន្ធចាត់តាំង និងកម្មវិធីសិក្សា គឺធ្វើឡើងទៅតាមតម្រូវការចាំបាច់របស់គ្រឹះស្ថានសិក្សា និងទៅតាមតម្រូវការរបស់អ្នកសិក្សា។ ចាប់ពីឆ្នាំ១៩៩៧ មកគ្រឹះស្ថានឧត្តមសិក្សាឯកជន បានកើតជាបន្តបន្ទាប់ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកសិក្សា ព្រោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ មិនអាចទទួលយកបានអស់នូវចំនួននិស្សិត ដែលកើនឡើងដ៏លើសលប់នេះ។ គេអាចវាយតម្លៃបានថា ទោះបីជាការអនុវត្តមិនបានត្រឹមត្រូវទៅតាមទ្រឹស្តីក៏ដោយ ក៏គេនៅតែទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់៕

---

**កំណត់សម្គាល់ឯកសារយោង ៖**

[1]ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ។

[2]ព្រះរាជក្រឹត្យ លេខ ១០៣ ន.ស. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ១៩៤៦។

[3]ព្រះរាជក្រឹត្យ លេខ ៥១៣ ន.ស. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ១៩៥៣។

[4]ព្រះរាជក្រឹត្យ លេខ ១២០ ប.រ. ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ ១៩៦២។

[5]ចាន់ រដ្ឋសុជា ៖ ប្រវត្តិអប់រំកម្ពុជា ភាគ ៣ ភ្នំពេញ ២០០៧ ទំព័រ ៣៨៧ ។

[6]ព្រះរាជក្រម លេខ ៨៧៩ ន.ស. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ១៩៥៤។

[7]ព្រះរាជក្រម លេខ ៦៣៨ ន.ស. ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ ១៩៥៥។

[8]ចាន់ រដ្ឋសុជា ៖ ប្រវត្តិអប់រំកម្ពុជា, សម័យសង្គមរាស្ត្រនិយម, ភ្នំពេញ ២០០៧។

[9]ចាន់ រដ្ឋសុជា ៖ ប្រវត្តិអប់រំកម្ពុជា ភាគ ៣ ភ្នំពេញ ២០០៧ ទំព័រ ៥៨៧។

[10]ចាន់ រដ្ឋសុជា ៖ ប្រវត្តិអប់រំកម្ពុជា ភាគ ២ ភ្នំពេញ ២០០៧ ទំព័រ ១៤៨។

[11]របាយការណ៍របស់ការិយាល័យអាហារូបករណ៍និងកម្មវិធីសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ ឆ្នាំ២០០៩។

[12] មួយក្រេឌីតស្មើនឹង ១៦ ម៉ោង។

[13]របាយការណ៍របស់នាយកដ្ឋានឧត្តមសិក្សា ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។

# ទស្សនាវដ្តីវិទ្យាសាស្ត្រ
# នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា

The scientific Journal of the International Relations Institute of Cambodia


| | | | |
|---|---|---|---|
| នាយកការផ្សាយ | ៖ បណ្ឌិត សុខ ទូច | Publisher | : Dr. Sok Touch |
| និពន្ធនាយក | ៖ លោក គិន ភា | Editor-in-chief | : Mr. Kin Phea |
| គណៈកម្មការនិពន្ធ | ៖ លោក ឯម សុវណ្ណារ៉ា | Editorial Committee | : Mr. Em Sovannara |
| | លោក ហ៊ាន ស្រស់ | | Mr. Hean Sras |
| | លោក យង់ ពៅ | | Mr. Yang Poeu |
| | លោក សូ មេន | | Mr. So Men |
| | លោក ហេង ប៊ុនសុង | | Mr. Heng Bunsong |
| ការីនិពន្ធ | ៖ លោក ប៊ុន ធឿន | Editorial Staff | : Mr. Bun Thoeun |
| | លោក កា ម៉ាធុល | | Mr. Ka Mathul |
| | លោក អៀង សាវឿន | | Mr. Ieng Savoeun |
| | លោក ឈុន ផាវ៉េង | | Mr. Chhun Phaveng |
| | លោក ពៅ ប៉ូលីណែល | | Mr. Poeu Polinel |
| គណៈកម្មការពិនិត្យអក្ខរាវិរុទ្ធ និងបកប្រែ ៖ | | Orthographic and Translation Team : | |
| | លោក តឹក មេង | | Mr. Tek Meng |
| | លោក ហុង វណ្ណៈ | | Mr. Hong Vanak |
| | លោក ឈត ប៊ុនថង | | Mr. Chhort Bunthang |
| | លោក សាន លាង | | Mr. San Leang |
| | លោក ឈឹម ផាន់ណា | | Mr. Chhim Phanna |
| ផ្នែកបច្ចេកទេស | ៖ លោកស្រី ហេង ដារី | Technical Team | : Mrs. Heng Dary |
| | លោក អ៊ុច លាង | | Mr. Uch Leang |
| ផ្នែកទីផ្សារ និងចែកផ្សាយ ៖ | | Marketing and Distribution Team : | |
| | លោក គី សេរីវឌ្ឍន៍ | | Mr. Ky Sereyvath |
| | លោក យូ គង្គា | | Mr. You Kungkea |
| | លោក លាវ ផារុន | | Mr. Leav Pharun |
| | លោក សុង ចំណាន | | Mr. Song Chamnan |
| | លោក ធន ឆាយពិសិដ្ឋ | | Mr. Thon Chhay Piseth |